# សេចក្តីថ្លែងការណ៍រួម ដោយ គ្រឹះស្ថាន អិលអូអិលស៊ី និង ដើមបណ្តឹង

នេះគឺជាសេចក្តីថ្លែងការណ៍រួម រវាង គ្រឹះស្ថាន អិលអូអិលស៊ី និង ដើមបណ្តឹង ពាក់ព័ន្ធនឹងការវិនិយោគដោយប្រយោលរបស់ IFC ជាមួយគ្រឹះស្ថាន អិលអូអិលស៊ី តាមរយៈទំនាក់ទំនងហិរញ្ញវត្ថុរបស់ស្ថាប័នទាំងនេះ ជាមួយ MIFA (លេខគម្រោង IFC #31467)។ ពាក្យបណ្តឹងនេះត្រូវបានដាក់ឈ្មោះសម្គាល់ថា "Cambodia MEF and MIFA Debt Fund 04"។

ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះ ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្សះផ្សាពេញលេញ និងជាស្ថាពរ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៤ ហើយក្រុមការងារសម្របសម្រួលរបស់ CAO បានតាមដានការអនុវត្តកិច្ចព្រមព្រៀងផ្សះផ្សានេះ រហូតដល់ខែធ្នូ ឆ្នាំ២០២៥។

ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តចំពោះលទ្ធផលនៃដំណើរការដោះស្រាយវិវាទ និងវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះ។ ភាគីទាំងពីរបានឯកភាពគ្នាបញ្ចប់ការតាមដានរបស់ CAO ។ ខណៈពេលដែលការចូលរួមរបស់ CAO ក្នុងការតាមដានកិច្ចព្រមព្រៀងផ្សះផ្សានេះបានបញ្ចប់ ភាគីទាំងពីរបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការបន្តអនុវត្តកិច្ចព្រមព្រៀងដោយសុចន្ទៈ សម្រាប់រយៈពេលដែលនៅសេសសល់នៃកិច្ចព្រមព្រៀង។

**កំណត់សម្គាល់៖** បញ្ហាដែលនៅសេសសល់នៅក្នុងសំណុំរឿង "Cambodia MEF and MIFA Debt Fund 04" ដែលពាក់ព័ន្ធនឹងអតិថិជនបន្តរបស់ IFC គឺ គ្រឹះស្ថាន ប្រាសាក់ (Prasac) នឹងត្រូវដោះស្រាយដាច់ដោយឡែក និងបន្តស្ថិតក្រោមការតាមដានការដោះស្រាយវិវាទរបស់ CAO ដដែល។

Official Use Only